# ដំណឹងជូនចំពោះគ្រួសារដែលកូនមានអត្តចរិកចម្លែក

## ដំណឹងសំខាន់ចំពោះគ្រួសារណាដែលរស់នៅក្នុងរដ្ឋ ម៉ាស្សាឈូសិត្ស ហើយមានកូនក្រោមអាយុ៩ឆ្នាំ ដោយបានរោគវិនិច្ឆ័យថាមានជម្ងឺអត្តវិស័យចម្លែក – ខែសីហា ឆ្នាំ២០១០

ផ្នែកអត្តចរិកចម្លែកនៃក្រសួងជនពិការបានចាប់ផ្តើមកម្មវិធីគំរូ, ដែលមានឈ្មោះថា កម្មវិធីផ្តល់សេវាកម្មដល់មនុស្សមានអត្តវិស័យចម្លែកនៅតាមផ្ទះនិងសហគមន៍ នៅក្នុងខែតុលា ឆ្នាំ២០០៧កន្លងទៅ។ កម្មវិធីនេះត្រូវបញ្ចប់នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០ ហើយកម្មវិធីចាប់ផ្តើមជាថ្មីទៀតនឹងជំនួសកម្មវិធីនេះដែលនឹងចាប់ផ្តើមឡើងនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១០។ កម្មវិធីចាប់ផ្តើមជាថ្មីនឹងបន្តផ្តល់អត្តភាគមន៍មួយទល់នឹងមួយ ដើម្បីជួយក្មេងមានអត្តចរិកចម្លែកដែលបង្ហាញឲ្យឃើញថាមានបញ្ហាយ៉ាងធ្ងន់ធ្ងរចំពោះចរិយាមាយាទ, សង្គម និងការប្រស្រ័យទាក់ទង តាមរយៈសេវាកម្មដែលមានឈ្មោះថា **បន្ថែមទទួលការមាននីតិសម្បទា, ការសិក្សាអប់រំ,** (សេវាកម្មនៅតាមផ្ទះ និងជំនួយដ៏ប្រពលលក្ខណៈ, ដូចជា ផ្តល់ការវិភាគផ្នែកចរិយាមាយាទ, ពេលវេលាកំសាន្ត និងការប្រស្រ័យទាក់ទងខ្នាតគំរូ)។ សេវាកម្មនេះកើតមានឡើងនៅក្នុងផ្ទះរបស់ក្មេង ឬនៅកន្លែងធម្មជាតិដទៃទៀតនៅក្រោមការគ្រប់គ្រងរបស់បុគ្គលិកពេទ្យដែលមានការហ្វឹកហ្វឺនស្ទាត់ជំនាញ។ កម្មវិធីនេះក៏នឹងផ្តល់សេវាកម្មគាំទ្រដទៃទៀតដែលជាប់ទាក់ទង ដូចជាសកម្មភាពរួមគ្នាក្នុងសហគមន៍ និងពេលសម្រាកសំរាប់មាតាបិតាផងដែរ។

សិទ្ធិអាចបន្តទទួលបាន នឹងបន្តផ្តល់សេវាដល់ក្មេងទាល់តែដល់អាយុគំរប់៩ឆ្នាំ, ដែលមានជម្ងឺអត្តវិស័យចម្លែក ហើយមានលក្ខណៈគ្រប់គ្រាន់សំរាប់កម្មវិធីចាប់ផ្តើមជាថ្មី។ រយៈពេលខ្លីក្រោយមក, ផ្នែកអត្តចរិកចម្លែក នឹងផ្តល់ជូននូវឱកាសដាក់ពាក្យសុំសំរាប់កម្មវិធីចាប់ផ្តើមជាថ្មីតាមរយៈពេលបើកចំហសំរាប់ការដាក់ពាក្យសុំ។ បុគ្គលិកផ្នែកអត្តចរិកចម្លែក ស្មានទុកជាមុនថាប្រហែលជាមានក្មេង៦០នាក់ថែមទៀត អាចមានសិទ្ធិទទួលបានកម្មវិធីក្នុងពេលការចុះឈ្មោះដំបូង ដែលនឹងមានពេលប្រហែល ១២-១៨ខែ។ បន្ទាប់ពីរយៈពេលនេះមក ក្រសួងនឹងបើកចំហការចុះឈ្មោះម្តងទៀត ដើម្បីធានាថាបញ្ជីនេះនៅតែទាន់សម័យ ហើយអនុញ្ញាតឲ្យក្មេងថ្មីទៀតដែលបានរោគវិនិច្ឆ័យរួចហើយ អាចមានសិទ្ធិទទួលកម្មវិធីចាប់ផ្តើមជាថ្មីបាន។

វត្ថុធាតុថ្មីនៅក្នុងកម្មវិធីចាប់ផ្តើមជាថ្មីគឺរក្សាទុកកន្លែងសំរាប់ក្មេងដែលមានអាយុ៣ឆ្នាំ ហើយផ្លាស់ប្តូរចេញពីកម្មវិធីអត្តភាគមន៍ដំបូង។ នេះមានន័យថា ផ្នែកអត្តចរិកចម្លែករក្សាទុក១០កន្លែង ពេញរដ្ឋទាំងមូល សំរាប់ក្មេងដែលមានអាយុ៣ឆ្នាំ។ ក្មេងទាំងនេះនឹងនៅតែត្រូវការជួបខ្នាតគំរូទាំងអស់ដែលជាប់ទាក់ទងនឹងហិរញ្ញវត្ថុនិងជម្ងឺប្រចាំខ្លួនដែលជាតម្រូវការសំរាប់ចូលនៅក្នុងកម្មវិធីនេះ។

កម្មវិធីចាប់ផ្តើមជាថ្មី អនុញ្ញាតឲ្យក្មេងបន្ថែមទទួលការមាននីតិសម្បទា, ការសិក្សាអប់រំ, (សេវាកម្មនៅតាមផ្ទះ និងជំនួយដ៏ប្រពលលក្ខណៈ, ដូចជា ផ្តល់ការវិភាគផ្នែកចរិយាមាយាទ, ពេលវេលាកំសាន្ត និងការប្រស្រ័យទាក់ទងខ្នាតគំរ) អស់រយៈពេលសរុប ៣ឆ្នាំ។ ចំពោះក្មេងដែលផ្លាស់ប្តូរចូលក្នុងកម្មវិធីចាប់ផ្តើមជាថ្មី, សេវាកម្មនៅតាមផ្ទះនិងជំនួយផ្សេងៗដែលមានរួចមកហើយ រាប់ទាំងអស់មានរយៈពេលបីឆ្នាំ។ នៅទីបញ្ចប់បីឆ្នាំនៃសេវាកម្មនៅតាមផ្ទះដ៏ប្រពលលក្ខណៈមក, ក្មេងអាចបន្តទទួលសេវាកម្មបន្ថែម (ពេលសម្រាកសំរាប់មាតាបិតា, អីវ៉ាន់ និងសេវាកម្មផ្សេងៗ ។ល។) ដែលជួបនូវសេចក្តីត្រូវការរបស់ក្មេង ហើយជួយផ្លាស់ប្តូរចេញពីកម្មវិធីចាប់ផ្តើមជាថ្មីដ៏ប្រពលលក្ខណៈ – ទាល់តែក្មេងដល់អាយុគំរប់៩ឆ្នាំ។

សេវាកម្មសិទ្ធិអាចទទួលបានទាំងអស់ តម្រូវឲ្យក្មេងបន្តជួបនូវតម្រូវការនានាដែលជាប់ទាក់ទងនឹងហិរញ្ញវត្ថុនិងជម្ងឺប្រចាំខ្លួន។

ដើម្បីផ្តល់សេវាកម្មថ្មីទាំងនេះ, នៅក្រោមកម្មវិធីចាប់ផ្តើមជាថ្មី ផ្នែកអត្តចរិកចម្លែកនឹងបើកចំហឲ្យមានដំណើរការដាក់ពាក្យសុំ ដើម្បីស្វែងរកក្មេងដែលមានសិទ្ធិអាចទទួលបានពាស់ពេញរដ្ឋ ម៉ាស្សាឈូសិត្ស ទាំងមូល។

**ដំណឹងនេះគឺដើម្បីជំរាបលោកអ្នកឲ្យដឹងអំពីតម្រូវការចំពោះសិទ្ធិអាចទទួលបានសំរាប់កម្មវិធីចាប់ផ្តើមជាថ្មី ៖**

**សិទ្ធិអាចទទួលបាន ៖** តម្រូវការទាំងឡាយនៅខាងក្រោមនេះគឺសំខាន់ណាស់ដើម្បីចូលរួមក្នុងកម្មវិធីនេះ ៖

1. ក្មេងនោះត្រូវតែមានបញ្ជាក់រោគវិនិច្ឆ័យថាមានជម្ងឺអត្តវិស័យចម្លែក (Autism Spectrum Disorder) ដែលរួមបញ្ចូលទាំងជម្ងឺអត្តចរិកចម្លែក (Autistic Disorder), ជម្ងឺកាចហួសហេតុ (PDD-NOS), រោគសញ្ញានៃជម្ងឺ Rhett, ជម្ងឺមិនចូលចំណោមគេចុះកើតមានតាំងតែពីវ័យក្មេង (Childhood Disintegrative Disorder), រោគសញ្ញាជម្ងឺ Asperger ដែលបានបញ្ជាក់ដោយក្រសួងជនពិការ។

2. ក្មេងដែលមិនទាន់ដល់អាយុ ៩ឆ្នាំ។ ក្មេងដែលមានអាយុ ៨ឆ្នាំអាចចូលរួមបាន។

# ដំណឹងជូនចំពោះគ្រួសារដែលកូនមានអត្តចរិកចម្លែក

3. ក្មេងដែលរស់នៅរដ្ឋ ម៉ាសាឈូសិត្ស។

4. ក្មេងដែលត្រូវការសេវាកម្មថែទាំនៅក្នុងមណ្ឌលថែទាំជាធម្មតាដោយសារតែភាពពិការផ្នែកសតិប្រាជ្ញា (ICF/ID) ដូចដែល**ក្រសួងជនពិការ**បានប្រមាណមើល។

5. គ្រួសារជ្រើសរើសឲ្យកូនទទួលសេវាកម្មនៅក្នុងផ្ទះ ហើយនិងនៅក្នុងសហគមន៍។

6. សហគមន៍ត្រូវតែផ្តល់សេវាដោយមានសុវត្ថិភាពដល់ក្មេង។

7. ក្មេងត្រូវតែមានអ្នកតំណាងដែលទទួលខុសត្រូវដោយស្របច្បាប់ ដែលអាចចាត់ការសេវាកម្ម និងការជួយគាំទ្រនៃសិទ្ធិដែលអាចទទួលនេះ។

8. ក្មេងត្រូវតែស្រាវជ្រាវឃើញដោយភ្នាក់ងារ ម៉ាស្សហែល ដើម្បីមានសិទ្ធិទទួលប័ណ្ណសុខភាព ម៉ាស្សហែល ខ្នាតគំរូដោយយោលទៅតាមប្រាក់ចំណូលគ្រួសារ។ ចំពោះគ្រួសារណាដែលមិនទាន់បានដាក់ពាក្យសុំប័ណ្ណសុខភាព ម៉ាស្សហែល នៅឡើយ, គ្រួសារនោះត្រូវតែដាក់ពាក្យសុំឲ្យទាន់ពេលការរៀបចំបំពេញក្រដាសស្នាមស្នើសុំសិទ្ធិអាចទទួលបាន។

នៅខាងក្រោមនេះគឺជាកម្រិតប្រាក់ចំណូលអតិបរមាណសំរាប់ប័ណ្ណសុខភាព ម៉ាស្សហែល ខ្នាតគំរូដែលមាន ១៥០% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធ។ ដើម្បីចូលរួមក្នុងកម្មវិធីចាប់ផ្តើមជាថ្មី, ប្រាក់ចំណូលរបស់គ្រួសារលោកអ្នកត្រូវតែក្រោមកម្រិតប្រាក់ចំណូលដែលបានរាយនៅខាងក្រោមនេះ*:

| ទំហំគ្រួសារ | ១៥០% កម្រិតភាពក្រីក្ររបស់សហព័ន្ធ | |
|---|---|---|
| | ប្រចំសប្តាហ៍ | ប្រចាំឆ្នាំ |
| ១ | ១,៣៥៤ ដុល្លារ | ១៦,២៥៨ ដុល្លារ |
| ២ | ១,៨២២ ដុល្លារ | ២១,៨៦៤ ដុល្លារ |
| ៣ | ២,២៨៩ ដុល្លារ | ២៧,៤៦៨ ដុល្លារ |
| ៤ | ២,៧៥៧ ដុល្លារ | ៣៣,០៨៤ ដុល្លារ |
| ៥ | ៣,២២៤ ដុល្លារ | ៣៨,៦៨៨ ដុល្លារ |
| ៦ | ៣,៦៩២ ដុល្លារ | ៤៤,៣០៤ ដុល្លារ |

*បើសិនកូនរបស់លោកអ្នកមានអាយុក្រោមមួយឆ្នាំ ឬមានលក្ខណៈជម្ងឺពិសេសដូចជា ខ្វាក់ភ្នែក, ថ្លង់ ឬមានជម្ងឺអស់កម្លាំងរ៉ាំរ៉ៃ ខ្នាតគំរូគឺខុសគ្នាពីកម្រិតដែលបានរាយនៅខាងលើ; សូមទាក់ទងផ្នែករោគអត្តចរិកចម្លែងដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ក្នុងករណីទាំងនេះ។

## របៀបចូលរួមក្នុងដំណើរការសិទ្ធិអាចទទួលបាន ៖

**1.** យកច្បាប់ចម្លងនៃក្រដាសស្នាមស្នើសុំកម្មវិធីចាប់ផ្តើមជាថ្មី

   a. សូមទាក់ទងមណ្ឌលគាំទ្រមនុស្សមានអត្តចរិកចម្លែក (មានរាយនាមនៅខាងក្រោម) ដើម្បីស្នើសុំក្រដាសស្នាមដាក់ពាក្យសុំ។
   
   b. មណ្ឌលគាំទ្រមនុស្សមានអត្តចរិកចម្លែកអាចជួយលោកអ្នកបំពេញក្រដាសស្នាមដាក់ពាក្យសុំ។
   
   c. ផ្នែកអត្តចរិកចម្លែក នឹងបិទប្រកាសក្រដាសស្នាមទាំងអស់នៅលើ វិបសៃត៍ របស់ក្រសួងជនពិការ ៖
   
      - **www.mass.gov/DDS** ក្រោមពាក្យ ‘Autism Spectrum Services’

**2.** បំពេញក្រដាសស្នាមដាក់ពាក្យសុំកម្មវិធីចាប់ផ្តើមជាថ្មី

ដើម្បីបំពេញក្រដាសស្នាមនេះ លោកអ្នកនឹងត្រូវការ ៖

   1. ថ្ងៃខែកំណើតរបស់កូនលោកអ្នក

# ដំណឹងជូនចំពោះគ្រួសារដែលកូនមានអត្តចរិកចម្លែក

2. លេខសំគាល់ខ្លួន **(SSN)** របស់កូនលោកអ្នក
3. លេខប័ណ្ណសុខភាព ម៉ាស្សហែល របស់កូនលោកអ្នក

3. បញ្ជូនក្រដាសស្នាមស្នើសុំកម្មវិធីចាប់ផ្តើមជាថ្មី រវាងថ្ងៃទី២០ ខែកញ្ញា ដល់ថ្ងៃទី១ ខែតុលា។
   - ក្រដាសស្នាមទាំងអស់ត្រូវតែមានត្រាវាយខាងលើ ឬថ្ងៃទីបិទតែម រវាងថ្ងៃទី២០ ខែកញ្ញា ដល់ថ្ងៃទី១ ខែតុលា។
   - ផ្នែកអត្តចរិកចម្លែកនឹងបោះចោលក្រដាសស្នាមផ្សេងៗ ក្រៅពីរយៈពេលដែលបានកំណត់ទុកនេះ។
   - សូមបំពេញក្រដាសស្នាមដោយប្រើប៊ិច ហើយបោះពុម្ពចេញឲ្យបានច្បាស់ល្អ។
   - សូមចុះហត្ថលេខាលើក្រដាសស្នាមដោយប្រើប៊ិច។
   - ពាក្យសុំមួយសំរាប់តែក្មេងម្នាក់ប៉ុណ្ណោះ – ផ្នែកអត្តចរិកចម្លែក នឹងបោះចោលក្រដាសស្នាមពហុគុណ
   - សូមផ្ញើក្រដាសស្នាមទៅឲ្យ (ផ្នែកអត្តចរិកចម្លែកមិនទទួលក្រដាសស្នាមដែលហុចដោយផ្ទាល់ដៃទេ) :

   **AUTISM DIVISION of DDS**
   **Att. Renewal Program Application Form,**
   **500 Harrison Avenue,**
   **Boston, MA 02118**

វាគឺជាអាទិភាពនៃផ្នែកអត្តចរិកចម្លែកនៃក្រសួងជនពិការ ដើម្បីធានាថាដំណើរការស្នើសុំកម្មវិធីអត្តចរិកចម្លែក អាចមានយ៉ាងពេញលេញចំពោះគ្រួសារ និងក្មេងដែលមានអត្តចរិកចម្លែក ដែលមានប្រវត្តភាសា និងវប្បធម៌ផ្សេងៗគ្នា។

ផ្នែកអត្តចរិកចម្លែកនៃក្រសួងជនពិការមានក្រដាសស្នាមដាក់ពាក្យសុំកម្មវិធីចាប់ផ្តើមជាថ្មីជាច្រើនភាសា។ សូមចូលទៅ វិបសៃត៍ របស់ក្រសួងជនពិការ ឬក៏ទូរស័ព្ទទាក់ទងមណ្ឌលគាំទ្រមនុស្សមានអត្តចរិកចម្លែកមួយក្នុងចំណោមប្រាំពីរកន្លែងដែលបានទទួលថវិកាពីក្រសួងជនពិការ ដែលមានភាសាអេស្ប៉ាញ, ភាសាហៃទី, ភាសាខ្មែរ, ភាសារុស្ស៊ី, ភាសាព័រទុយហ្គាល់ និងភាសាចិនម៉ង់ដារិន។

សេចក្តីប្រកាសនេះ និងពត៌មានសិទ្ធិអាចទទួលផ្សេងទៀត គឺមាននៅលើ វិបសៃត៍ របស់ក្រសួងជនពិការ www.mass.gov/DDS ក្រោមពាក្យ 'Autism Spectrum Services' ហើយនិងនៅតាមមណ្ឌលគាំទ្រមនុស្សមានអត្តចរិកចម្លែកដទៃទៀតដែលក្រសួងជនពិការបានផ្តល់ថវិកា។ សំរាប់ពត៌មានបន្ថែមអំពីកម្មវិធីអត្តចរិកចម្លែក, សូមទូរស័ព្ទមកលេខដែលឥតគិតថ្លៃ : 1-(888) 367-4435។

### បញ្ជីរាយនាមមណ្ឌលគាំទ្រមនុស្សមានអត្តចរិកចម្លែក :

**មណ្ឌលធនធានមនុស្សមានអត្តចរិកចម្លែក :**
71 Sterling Street, West Boylston, MA 01583
#508-835-4278: Serving: Central, MA

**ធនធានសហគមន៍សំរាប់មនុស្សមានអត្តចរិកចម្លែក :**
116 Pleasant St. Easthampton, MA 01027
#413-529-2428: Serving Western, MA

**ធនធានសហគមន៍សំរាប់មនុស្សមានអត្តចរិកចម្លែក :**
33 James Reynolds Rd, Unit C, Swansea, MA 02777
#508-379-0371: Serving Southeastern, MA

**TILL and Boston Families for Autism**:
20 Eastbrook Rd. Dedham, MA 02026
#781-302-4600 x 4661: Serving Greater Boston

**មណ្ឌលគ្រួសារសំរាប់មនុស្សមានអត្តចរិកចម្លែក :**
789 Clapboardtree Street, Westwood, MA 02090
#781-762-4001, X. 395 Serving Norfolk County Area

**NEARC: មណ្ឌលធនធានមនុស្សមានអត្តចរិកចម្លែក :**
6 Southside Road, Danvers, MA 01923
#978-777-9135: Serving Northeastern, MA

**មណ្ឌល ឆាលស៍ រីវ័រ – Charles River Center:**
59 East Militia Heights Road, Needham, MA
# 781-972-1048: Serving MetroWest